# ការសំភាសន៍ជាលើកទី២របស់លោកពូពៅ សុខា

កៈ អ្នកដែលសំភាសន៍ ញ៉ែម សុគន្ធា ខៈ អ្នកដែលត្រូវគេសំភាសន៍ពៅ សុខា

## <u>ការសង្ខេបរបស់លោកពូពៅ សុខា</u>

នៅក្នុងការសំភាសន៍ជាលើកទី២នេះលោកពូបានរៀបរាប់ពីជីវិតដែលគាត់បានសិក្សាថាគាត់រៀនបានប្រលងឌីផ្លូម ហើយគាត់មានបំណងប្រាថ្នាជាគ្រូបង្រៀនអក្សរសាស្រ្តដើម្បីដឹងពីប្រវត្តិនៃប្រទេសជាតិអោយកាន់តែច្រើន។ លោកពូបានកើតទាន់ជំនាន់សង្គ្រាមហើយការហូបចុកគឺសឹងតែគ្រប់ពេលដែលពិបាក ការហូបស្រួលមានតែបន្តិចតែប៉ុណ្ណោះ ពូបានរៀបរាប់ពីការជំលៀសនៅពេលដែលពួកលន់នល់ នឹងប៉ុល ពតបានធ្វើសង្គ្រាមជាមួយគ្នាហើយធ្វើអោយប្រជាជនលំបាក។ នៅក្នុងរបបប៉ុល ពត ប្រជាជនត្រូវបានរងទុក្ខយ៉ាងខ្លាំងហើយបងប្អូនសាច់ញាតិត្រូវបានស្លាប់យ៉ាងច្រើន។លោកពូមានបំនងចង់អោយកូនចៅជំនាន់ក្រោយរៀនបានអោយច្រើនដើម្បីគេចផុតពីភាពល្ងង់ខ្លៅហើយត្រូវថែរក្សាទឹកដីដើម្បីកុំអោយគេយកទឹកដីខ្លួនបាន។

កៈ ជាដំបូងនាងខ្ញុំសូមថ្លែងអំណរគុណលោកពូជាលើកទី២ដែលគាត់បានអោយសំភាសន៍ដំពីជីវប្រវត្តិលោកពូជាលើកទី២ នាងខ្ញុំឈ្មោះញ៉ែម សុគន្ធា ជាសំភាសន៍អំពីជីវប្រវត្តិលោកពូនៅក្នុងថ្ងៃនេះ ពួកយើងសំភាសន៍គឺនៅក្នុងខែ កុម្ភៈ ឆ្នាំ២០១៨។ ការសំភាសន៍មានទីតាំងស្ថិតនៅក្នុងភូមិកោះក្របី សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ប្រទេសកម្ពុជាអ៊ីចឹងនាងខ្ញុំសូមសួរលោកពូអំពីកន្លែងដែលលោកពូអត់ទាន់បាននិយាយអ៊ីចឹងពីជីវិតរបស់លោកពូ!!អ៊ីចឹងលោកពូចូលដល់ការសិក្សារបស់លោកពូ លោកពូរៀនបានថ្នាក់ទីប៉ុន្មានដែរលោកពូ?

ខៈ កាលហ្នឹងទី ៧ អស់ថ្នាក់រៀន។

កៈ ម៉េចអ៊ីចឹងវិញ?

ខៈ ចុះរត់អស់ហើយ។

កៈ រត់!!

ខៈ ទី៨យប់ឆ្លងដរអត់អ្នកណាទៅ។កៈ ហ្ហ៎!!ខៈ កាលហ្នឹង៨៤(១៩៨៤)៨៥(១៩៨៥)អស់ហើយទី៧ហ្នឹង។

កៈ ហ៊ុៗ!!

ខៈ កាលេសកាលេសមកទី៧ហ្នឹង!!

កៈ ចាំ!!ជំនាន់មុននេះហ្នឹងមែន មុនសង្គ្រាមឬក៏ក្រោយសង្គ្រាម?

ខៈ បែកហើយហ្នឹង!!

កៈ បែកហើយហ្នឹង?

ខៈ ជំនាន់ ហេង សំរិនហ្នឹង។

កៈ ហេង សំរិនហេ គេហៅរដ្ឋកម្ពុជាហ្នឹងហេពូហេ?

ខៈ ហ្នឹងហើយហ្នឹងហើយ កម្ពុជា សាធារណៈរដ្ឋកម្ពុជា។

កៈ ចាំ គេរៀនមានតែថ្នាក់ទី៧ទេ?ឡើងទៅទៀតដល់ទី១២អត់មានម៉ង?

ខៈ អត់ទេ!!មានបំពេញវិជ្ជាយប់ កាលហ្នឹងឆ្លងដរទៅរៀននៅតាខ្មៅ។

(ភរិយារបស់លោកពូ)៖ ថ្នាក់១២ក៏មានដែរតែគេប្រលងយកកៅអីហី?

ខៈ អត់ទេ អត់ទេ។

(ភរិយារបស់លោកពូ)៖ប្រលងយកកៅអីហី?

ខៈ អត់ទេជំនាន់ហ្នឹងត្រឹមទី៧ហ្នឹង។

កៈ អ៊ីចឹងពូរៀន ពីមុនសង្គ្រាមពូធ្លាប់រៀនខ្លះនៅ?

ខៈ ពេលសង្គ្រាមយើងរត់សង្គ្រាមយើងមានរៀនណា។

កៈ មុនហ្នឹងអត់ទាន់ទេហោ?

ខៈ អត់ទាន់។

កៈ ដល់បែកហើយបានបានរៀន។

ខៈ ហ្នឹងហើយ។

កៈ ពូរៀននៅសាលាអីគេឈ្មោះអីគេវិញ?

ខៈ រៀននៅកោះក្របី។

កៈ បឋមសិក្សាកោះក្របីពូហោ?

ខៈ ប្រលងកាលេស ប្រលងនៅតាខ្មៅ។

កៈ ហ៊ុន សែន តាខ្មៅយើងហ្នឹង?អ៊ីចឹងហ៊ុន សែន តាខ្មៅអ៊ីចឹងពេលបែកមកហើយគេបង្កើតហើយហើយហោ?

ខៈ អត់មានទេ។

កៈ អត់ទាន់ទេហោ?

ខៈ គេហៅសាលាមិត្តភាព។ហៅសាលាលិចទឹក។

កៈ អាហ្នឹងសេរីភាពទេពូហី?

ខៈ ហ្នឹងហើយសេរីភាព។

កៈ ហ្នឹងហើយ អ៊ីចឹងហ៊ុន សែន តាខ្មៅអត់ទាន់មានទេ!!

ខៈ ហ្នឹងហើយ។

ក៖ ចំលិចទឹកកើតមុន?

ខ៖ ហ្នឹងហើយ សាលាពីសង្គមចាស់!!

ក៖  ចា!!  អ៊ីចឹងលោកពូពេលលោកពូរៀនអំពីនេះហាំពេលរៀនហ្នឹងក្ដីស្រម៉ៃរបស់លោកពូហាំពេលធំឡើងថាលោកពូចង់ក្លាយជាអីគេមួយទេ?

ខ៖ កាលហ្នឹងចិត្តមានអារម្មណ៍ចង់ធ្វើគ្រូបង្រៀន។

ក៖ គ្រូបង្រៀនដែរហោ?

ខ៖ គ្រូខ្មែរ។

ក៖ ចាំ!

ខ៖ គ្រូខ្មែរ បង្រៀន។

ក៖ ហើយមានបានប្រលងចូលទេពូពេលហ្នឹង?

ខ៖ កាលហ្នឹងគេអោយដាក់ពាក្យ អ្នកខ្លះគេដាក់ពាក្យចូននគរបាលទៅតែពួកញ៉ុមប្រលងដែរប្រលងចូលគ្រូ បានរៀនគរុកោសល្យដែរហ្នឹង។

ក៖ ចាំ!!

ខ៖ តែគ្រាន់តែអោយដូចអត់ អត់ន័យអី។

ក៖ ម៉េចអ៊ីចឹងវិញពូ?

ខ៖ វាគេទារ ទារថ្លៃថ្លៃពេកឪពុកម្ដាយម្នាក់ៗអត់មានសមត្ថភាពគ្រាន់តែសញ្ញាបត្រ័ទារមួយដំឡើងកន្លះ ១ដំឡឹង៥ជីហាំ!!

ក៖ ចាំ!!

ខ៖ ជំនាន់ហ្នឹងមានមកពីណា ក្រ!!

ក៖ ហ៊ឺ!!

ខ៖ ក៏អ៊ីចឹងក៏អត់យកទៅ ខ្លះគេចូលទាហាន ធ្លាប់ចូលដែរហ្នឹងទាហាន។

ក៖ ចាំ!!

ខ៖ ចេះតែចូលចូលតាមគេទៅ។

ក៖ ពេលហ្នឹងគេចាប់ទាហានពូមានទៅទេ?

ខ៖ គេចាប់ខ្លាំងញ៉ុមនៅសិស្ស នៅសិស្សសាលា សិស្សសាលាដល់ពេលហើយបានមានគ្រួសារគេចាប់ចាប់បានស្មគ្រ័ចិត្ត ស្មគ្រ័មួយសារឈប់ ស្មគ្រ័ចិត្តឈប់មានគ្រួសារបានបងគាត់ហៅចូលទៅ
យើងធ្វើនៅប៉េ៨៥កាច់ជ្រុងយើងនៅវត្តស្វាយពពៃនេះមាត់ទន្លេនេះ ហ្នឹងប៉េ៨៦ ខាងរត់សាររត់អី។

ក៖ ចាំ!!

ខ៖ យកទៅពោធិ៍សាត់ បាត់ដំបងអី ។

ក៖ ហ៊ឺៗ!!

ខ៖ ញ៉ុមពិបាកដែរ។

ក៖ អ៊ីចឹងលោកពូពេលលោកពូបានរៀនចប់បានចប់គរុកោសល្យដែរអ៊ីចឹងពូណោះ?

ខ៖ បានដែរ។

ក៖ អ៊ីចឹងដោយសារពេលហ្នឹងពួកអ្នកបានធ្វើជាគ្រូបង្រៀនទេ ពូបានចូលធ្វើអីគេវិញទៅពេលហ្នឹង?

ខ៖ ចូលធ្វើទ័ព។

ក៖ ធ្វើពេលហ្នឹងតែម្តងទៅ?

ខ៖ ហ្នឹងហើយ។

ក៖ ស្មគ្រ័ចិត្តខ្លួនឯងឬក៏ម៉េចកាលហ្នឹង?

ខ៖ កាលហ្នឹងមិនស្មុគ្រ័ទេ បងហៅ ហៅធ្វើទៅគាត់ស្គាល់ធ្វើ ធ្វើកន្លែងស្រួលដែរ តែចង់ដឹងគេបបួលទៅភារកិច្ចគេហៅថារត់ប្រៃណីយ៍ជំនាន់ហ្នឹង។

ក៖ ចាំ!!ដូចពូប្រាប់មិញអីចឹង!!

ខ៖ ហ្នឹងហើយ។គេថាយើងទៅដឹអិនហ្នឹងទៅរត់ឯកសារហាំ!!

ក៖ ចាំ!!

ខ៖ ទៅរត់ឯកសារយើងចេះបារាំងតិចៗយើងមើលសំណុំបែបបទសំខាន់ៗយើងដឹង ដល់ពេលមកអង្គភាពយើងដឹងអិចឹងទៅយើងដឹងដឹងហើយដឹងថាឯកសារសំងាត់ហ្នឹងយើងត្រូវទំពារលេប។

ក៖ ហ៊ឺៗ!!ខ៖ ទំពារលេប?

ខ៖ អាហ្នឹងគេដឹងទីតាំងយើងណោះ ទៅ!!

ក៖ ឯកសារសំងាត់ពីអីគេទៅពូ?

ខ៖ ក្បួនធ្វើសឹកធ្វើអីហ្នឹងតាមមើលទៅ។

ក៖ ចាំ!!

ខ៖ កុំអោយពួកខ្មែរក្រហមវាដឹងអីណានេះយើងយកពីភ្នំពេញទៅពោធិ៍សាត់ បាត់ដំបងអីទៅណាស់ ហើយគេយកពីសមរភូមិទៅ។

ក៖ តទៀតទៅ!!ដឹងឯកសារស្អីគេទេពូហេ??

ខ៖ អាហ្នឹងឯកសាររបៀបទីតាំងហាំ!!

ក៖ ហ៊ឺៗ!!

ខ៖ ទីតាំងគេអត់អោយចាប់បានទេអាហ្នឹងហ្នំ!!ដូចក្នុងសំបុត្រការហាំ!!

ក៖ ចាំ!!

ខ៖ ហើយគេវ៉ៃអង្គុលីលេខស្តើងមូលទៅប៉ុននេះទេហ៎!!

ក៖ ហ៊ឺ!!

ខ៖ ទំពារលេប ញ៉ុម វាម៉េចអោយទូកធ្វើម៉េចកុំអោយដានមើលកើតហា៎!! ទៅចាប់ម៉េចបានស្គាល់ទីតាំងយើង។អាហ្នឹងវាអ៊ីចឹង។

ក៖ ហ៊ឺ!!ពូពេលពូនៅរៀនពូមានមិត្តភក្តិជិតស្និតអីអត់ ពេលសិក្សា?

ខ៖ មានតើ!!មិនមែនអត់ទេមាន។

ក៖ នៅរាប់អានគ្នាដល់ឥឡូវទេ?

ខ៖ បាទ!!

ក៖ គាត់ឈ្មោះអីគេដែរមិត្តភក្តិរបស់ពូ?

ខ៖ មិត្តភក្តិឈ្មោះម៉ន ឈ្មោះភឿនអី ច្រើនដែរមិត្តភក្តិស្រីៗអីក៏មានដែរ។

ក៖ ហើយឥឡូវពួកគាត់ទៅណាអស់ហើយបែកខ្ញែកគ្នាទៅណាអស់ហើយឬក៏នៅហ្នឹងទេ?

ខ៖ ហ្វ៎គេមានគ្រួសារខ្លះគេមានប្តីមានប្រពន្ធទៅ ខ្លះគេនៅតាមខេត្តអីអ៊ីចឹងទៅណាស់។

ក៖ ចា៎!!

ខ៖ ចេះតែនឹកគ្នាដែរហ្នឹង!!

ក៖ ហើយ!!

ខ៖ ខ្លះ!!

ក៖ ម៉េចដែរពូ?

ខ៖ ជួបគ្នាខ្លះបើមិត្តភក្តិស្រីៗជួបគ្នាអត់ហ៊ានជួបគេទេ ។

ក៖ ម៉េចអៀនទៅហេ?

ខ៖ ខ្លាចប្ដីគេប្រចណ្ឌ័។

ក៖ ណោះក៏ខ្លាចប្រពន្ធប្រចណ្ឌ័ណោះក៏ខ្លាចអើរប្ដីប្រចណ្ឌ័អ៊ីចឹងទៅពូណោះ?

ខ៖ ហ្នឹងហើយពូឥឡូវចូលដល់ជីវិតអាពាហ៍ពិពាហ៍របស់ពូវិញម្ដង មិញការសិក្សាចប់ហើយពូមានអីពីការសិក្សាទៀតទេ?

ខ៖ អត់។

ក៖ អស់ហើយត្រឹមហ្នឹងទេហេ?

ខ៖ អស់ហើយ។

ក៖ អ៊ីចឹងចូលដល់ជីវិតអាពាហ៍ពិពាហ៍អ៊ិចឹងពូរៀបការនៅឆ្នាំណាវិញ?

ខ៖ ឆ្នាំ១៩៨៦ ៨៦។

ក៖ ហ្ហ៎ អាយុប៉ុន្មានពេលហ្នឹងពូរៀបការ?

ខ៖ ២២។

ក៖ ២២ឆ្នាំហេ?

ខ៖ បាទ!!

ក៖ ល្មមប៉ុណ្ណឹងហេ!!ដូចពុកញ៉ុមការ២២ដែរ ។

ខ៖ កាលហ្នឹង ក្នុងអីមិនទាន់សំបូរទេ ភាគច្រើន ភាគច្រើនធ្វើសក់នៅអីតាខ្មៅឆ្លងដរទៅហា៎!!

ក៖ ចា៎ការហ្នឹងមានរោងអីត្រឹមត្រូវទេពូ?

ខ៖ ហេអត់មានរោងអីដូចឥឡូវទេ!!គេធ្វើដូចមានកៅស៊ូប៉ាតង់អីអាបារម្លូអីគេទិញមកចេះតែសហាការគ្នាមកណាស់ ធ្វើទៅធ្វើដូចពីសង្គមអ៊ីចឹងហា៎!!

ក៖ ចា៎!!

ខ៖ មិនមែនដូចឥឡូវជំបូលគេទំនើបៗទេ!!ជំនាន់ហ្នឹងហ្ហ៎!!

កៈ ឥឡូវហ្នុំតែងផ្កាពេញរោង។

ខៈ ពេលហ្នឹងអត់ទេ កាលហ្នឹងស្លឹកម៉ាសែអីហ្នឹង។

កៈ ចាំតែរោងអីអ៊ីចឹងទៅពូណោះ?

ខៈ ហ្នឹងហើយ ស្លឹកម៉ាសែដាក់មុខអាក្លោងទ្វារចូល!! ផាងដូចអីទៅណាស់!!ដាក់សប់ប៉េតប៉ោងអីទៅ!!

កៈ មានប៉េតប៉ោងអីពេលហ្នឹងដែរហោ?

ខៈ មាន។

កៈ អ៊ីចឹងពូពេលការពូមានអោយថ្លៃជំនូនទៅខាងមីងអត់?

ខៈ អត់ទេ។

កៈ ហ៊ឺ!!

ខៈ ការទាំងអស់គ្នាទៅ។

កៈ អត់មានអោយផ្ទះ៣ខ្នងអីអត់ទេហី??

ខៈ អត់ទេ មិនមែនដូនគេឥឡូវ ទាសុទ្ធតែរាប់ពាន់អីហ្នុំ!!ជំនាន់ហ្នឹងអត់ទេ។

កៈ
ពេលហ្នឹងថ្លៃជំនូនអីរ៉ាន់ថ្លៃទឹកដោះអីរ៉ាន់អត់មានម៉ងហើយពូហោ?គឺគ្រាន់តែបានរៀបកការជាមួយគ្នាទៅ?

ខៈ ហ្នឹងហើយ។

កៈ
ហើយពេលរៀបការជាមួយមីងដោយសារឪពុកម្ដាយជាអ្នកស្ដីដណ្ដឹងអោយដោយបង្ខិតបង្ខំអីឬក៏ស្រលាញ់គ្នាដោយចិត្តឯង?

ខៈ យល់ចិត្តគ្នាទៅវិញទៅមកទៅ។

កៈ អីយ៉ាស់ !!ជួបគ្នាដំបូងនៅឯណា?

ខៈ រៀន ធ្លាប់រៀនជាមួយគ្នា។

កៈ ហើយ៉ាស់!!ល្អូច!!

ខៈ ដល់កាលេសបែកគ្នាទៅប្រលងកាលេស។

កៈ ចាំ!!

ខៈ ញុំមទៅតាខ្មៅទៅ។

កៈ ហើយមីងឈប់រៀនទៅ?

ខៈ គេរៀន រៀនបានប៉ុណ្ណឹង។

កៈ ហើយពូពេលជួបមីងដំបូងនៅណា ពេលរៀននៅសាលាឬក៏នៅផ្ទះជាប់គ្នា?

ខៈ ផ្ទះនៅភូមិជាមួយគ្នាហ្នឹង។

កៈ ភូមិជាមួយគ្នាហ្នឹងហេ??

ខៈ ទៅរៀនសាលាជាមួយគ្នាហ្នឹងទៅ!!

កៈ ចាំ!!អីចឹងស្គាល់គ្នាតាំងពីក្មេងៗមកហើយ??

ខៈ ហ្នឹងហើយ។

កៈ ហើយចាប់ផ្តើមស្រលាញ់មីងពេលណា?

ខៈ អត់ចាំ។

កៈ ហេ!!ដល់ពេលសួរចំត្រូវរឿងអត់ចាំ។ មីងស្រលាញ់ពូពេលណា?

ខៈ ញុំមស្រលាញ់មិនមែនដូចក្មេងពីឥឡូវនេះទេ អៀនគ្នាសឹងងាប់ហើយហ្នឹង!!

កៈ ចាំហ្នឹងហើយ។

ខ៖ គ្រាន់តែស្រលាញ់គ្នាចិត្តនឹងចិត្តហ្នឹង។

ក៖ ចាំ!!

ខ៖ មិនមែនដូចឥឡូវ!!

ក៖ ចាំ ហើយដល់ពេលអ៊ីចឹងទៅអោយចាស់ៗទៅស្ដីដណ្ដឹងទៅពូហោ?

ខ៖ ហ្នឹងហើយ។

ក៖ ហ្នឹងហើយ។

ខ៖ ធម្មតាហ្នឹង។

ក៖ អ៊ីចឹងក៏!!ពូពេលរៀបការជាមួយមីងមក មានកូនប្រុសស្រីប៉ុន្មាននាក់ដែរ?

ខ៖ ៤នាក់ នោះបងគេ។

ក៖ ចាំ!!បងមុំបងគេ!!អ៊ីចឹងស្រីប៉ុន្មានប្រុសប៉ុន្មានដែរពូ?

ខ៖ ស្រី៣ប្រុស១។

ក៖ ចាំ!!ស្រី៣ប្រុស១។ហ៊ីបានស្រីច្រើនដែរ!!អូខេពូអាចប្រាប់ឈ្មោះកូនទាំងអស់បានទេ?ឈ្មោះអីគេខ្លះអ៊ីចឹងហាំ!!ពីបងគេរហូតដល់ពៅគេហាំ??

ខ៖ ពៅ ស្រមុំ ពៅ វ៉ាន់ចាន់ ពៅ ចាន់ធឿន ពៅ ចាន់ធូ។

ក៖ ចាន់ធូ!!ហ្នឹងហើយ ឥឡូវពួកគាត់នៅណាវិញពូ ទាំង៤នាក់នៅជាមួយគ្នាទាំង៤នាក់ឬក៏ទៅណាខ្លះហើយ?

ខ៖ អត់ទេគេមានគ្រួសារ អាមួយការនៅភ្នំពេញនៅភ្នំពេញទៅមុំនៅផ្ទះ។

ក៖ ចាំ!!អ៊ីចឹងទាំង៤នាក់ហ្នឹងគឺថារៀបការហើយអស់រលីងម៉ងហោ?

ខ៖ នៅមួយ។

កៈ ហ៊ីៗ!!នៅពៅគេឬក៏ម៉េចដែរ?

ខៈ នៅបន្ទាប់ពៅ។

កៈ បន្ទាប់ពៅ ពៅគេការហើយវិញ។

ខៈ ហ្នឹង!!

កៈ ពៅគេនេះវិញ ឬក៏មែនវិញ?

ខៈ មិនមែនទេ ក្មួយ។

កៈ ក្មួយទេនេះហោ!!អ៊ីចឹងលោកពូសំរាប់កូនរបស់លោកពូដែលគាត់ទាំងបួននាក់ហ្នឹង ពូមានអោយគាត់ទៅរៀនទាំងអស់គ្នាអត់?

ខៈ រៀនតើ!!

កៈ
ពូគិតថាការសិក្សាមានន័យយ៉ាងម៉េចដែរដែលពូបានបញ្ជូនកូនក៏ដូចជាខ្លួនឯងបានរៀនហា៎??

ខៈ មានតំលៃតើការសិក្សា។

កៈ ម៉េចដែរពូ គិតម៉េចដែរបានថា តើការសិក្សាជួយឆ្លុះបញ្ចាំងអីគេដែរតាមគំនិតពូហា៎??

ខៈ
ការសិក្សាគឺធ្វើអោយយើងមានប្រាជ្ញាធ្វើអោយយើងមានចេះដឹងដឹងសរដឹងខ្មៅធ្វើអោយយើង ហ្នឹងកុំអោយអវិជ្ជា កុំអោយថាកន្លែងណាល្ងង់យើងកុំទៅអ៊ីចឹងទៅណាស់!!

កៈ ចា៎!

ខៈ អាតំរិះវិជ្ជាវាសំខាន់ណាស់!ជាមាសប្រាក់របស់យើងហា៎!!

កៈ ចា៎!!

ខៈ យើងមានវាទៅមានប្រាក់ខែខ្ពង់ខ្ពស់ហើយយើងទៅវាស្រួលរបស់គាត់ទៅ ។

ក៖ ហ៊ឹៗ!!

ខ៖ សម័យឥឡូវអ្នកណាគេមានតំរិះវិជ្ជាខ្លាំងប្រាក់ខែក៏ច្រើនដែរស្រួល។

ក៖ ហ៊ឹៗ!!

ខ៖ អាហ្នឹងវាច្រើនក្ងបផ្សំគ្នាទៅវិញទៅមកហាំ!!

ក៖ ហ្នឹងហើយ។

ខ៖ ឥឡូវលោកពូចូលដល់ពេលនេះវិញម្តង ចូលជីវិតរបស់លោកពូដែលឆ្លងកាត់របបសង្គ្រាមដោយសារលោកពូអាយុ៥៣ឆ្នាំហើយអ៊ីចឹង ការឆ្លងកាត់សង្គ្រាមហ្នឹងពូសុទ្ធតែឆ្លងកាត់ហើយមែនទេ??

ខ៖ កាលហ្នឹងឆ្លងកាត់កំពុងពេញចូលរៀនដែរ ធ្វើអោយអត់បានរៀន។

ក៖ ដល់ពេលអញ្ចឹងបានកាត់ផ្តាច់ប្រពន្ធ័អប់រំទាំងអស់ម៉ងទៅពូហោ?

ខ៖ ហ្នឹងហើយ !!

ក៖ ចាំ!!

ខ៖ យើងដឹងក្តីចូលអង្គភាពគេអោយរៀនមួយម៉ោងៗពេលហ្នឹងជំនាន់អាពតហ្នឹងរៀននៅក្រោមដើមឈើ។

ក៖ ហើយគ្រូបង្រៀនចេះជាងអត់?

ខ៖ ចេះជាងយើងតិចដែរហ្នឹង គេធ្លាប់រៀនពីដើមមុនមកហាំ!!រៀននៅក្នុងជំនាន់អាពត។

ក៖ ចុះក្រែងគេថាអ្នកដែលចេះយកទៅសម្លាប់ចោលហោ ហើយម៉េចក៏មានគ្រូបង្រៀន?

ខ៖ ចេះអាពួកអ្នករៀនមុនៗយើងចេះប្រកបធ្វើជើងព្យញ្ជនៈអីហ្នឹង ក កា កិ កីហ្នឹង យើងអត់ចេះ ចេះតែទៅហើយចង់ចេះ កាលហ្នឹងក្តារវាសំបកគរហ្នឹង។

ក៖ ចាំ!

ខ៖ ហើយដីឥដ្ឋយើងហ្នឹង។គូរទៅ។

ក៖ ហ៊ីចេះតែគូសរៀសគូសរៀសទៅពូណោះ?

ខ៖ ហើយអង្គុយតំរង់ជួរគ្នាសរសេរទៅ ដាក់ក្តារលើខ្នង់ទៅសរសេអក្សរ។

ក៖ ចាំ!!

ខ៖ ចង់ចេះអត់អោយយើងរៀនច្រើន។

ក៖ ហ៊ីៗ!!

ខ៖ មេលេខហ្នំសូត្រឡើងបែកពពុះមាត់!! មេលេខអោយចេះណាស់ដល់អក្សរវាអត់អោយច្រើនទេ។

ក៖ ចាំ!

ខ៖ និយាយរួមត្រឹមតែចេះម៉ាសរសេរឈ្មោះខ្លួនឯង។

ក៖ ហ៊ីៗ!!

ខ៖ ប៉ុណ្ណឹងអស់ហើយ។

ក៖ ហេការសិក្សាគេនេះក៏ឧដុង្គឧតុង្គម្ល៉េះ ។

ខ៖ បាទ!!

ក៖ អ៊ិចឹងពូមុននឹងចូលដល់ជំនាន់ប៉ុល ពតមុននឹងលោកពូរៀបរាប់អ៊ីចឹងនិយាយពីជំនាន់លន់នល់ តើពូបានដឹងអីគេខ្លះពីជំនាន់លន់ នល់ដែរ?

ខ៖ ញ៉ុមដឹងតែធ្វើសង្គ្រាម ញ៉ុមដឹងតែមិតគ្រាប់ផ្លោងអីអ៊ីចឹងទៅ!!

ក៖ ចាំ!!

ខ៖ ឪពុកម្ដាយនាំទៅណាទៅហ្នឹងហើយ!! យប់ឡើងស្មើរហ្នឹងហូបបាយហើយហើយវេចបង្វិចហាំ!!ចាំរត់ហាំ!!ជាពិសេសរត់ចូលក្រោមវត្តច្បារអំពៅ ។

ក៖ ចាំ!!

ខ៖ ណែន!!

ក៖ ហូយ!!

ខ៖ គ្រាប់ផ្លោងជាធ្លាក់អត់ត្រូវហាំ!!

ក៖ ហ្នឹងសុវត្ថិភាពជាងគេហើយពូហោ?

ខ៖ ហ្នឹងហើយ។

ក៖ ចាំ!!ពូពេល!!

ខ៖ ជំនាន់ហ្នឹងពិបាក ពិបាក។

ក៖ ហ្នឹងហើយ!! នៅនេះគេផ្លោងត្រូវទេ??

ខ៖ អត់ទេហួស ពីតាខ្មៅទៅហួសណោះ!!

ក៖ ទៅហួសដល់កោះអន្លង់ចិនអីពូណោះ??

ខ៖ ទៅដល់ព្រែកដូងកំពង់ស្វាយហ្នូំ!!

ក៖ ហ្នុំនៅឆ្ងាយ!!

ខ៖ ខ្មែរក្រហមនៅហ្នឹង ខ្មែរក្រហមនៅហ្នឹង។

ក៖ ហ្នុំ!!

ខ៖ វាគៀរយើងត្រឹមហ្នឹងទៅទុកណោះកោះធំអីហ្នុំ!!ព្រែកតូចអីណោះពួកខ្មែរក្រហមឡើងមកមកវៃជាមួយលន់ នល់។

ក៖ ចាំ!!

ខ៖ មកកោះក្របីនេះ។

ក៖ អ៊ីចឹងគោលបំណងរបស់លន់នល់ហ្នឹងគឺវែជាមួយខ្មែរក្រហមហ្នឹងហេ?ពូខ្មែរក្រហមហ្នឹងកើតមកពីអ្នកណាគេវិញ?អ្នកណាគេជាអ្នកដឹកនាំអោយចេញជាខ្មែរក្រហមដោយសារ លន់នល់គាត់ទំលាក់សម្តេចដើម្បីគាត់បានអំណាចពេលខ្មែរក្រហមអ្នកណាគេជាអ្នកបង្កើតមកវិញ?ពូដឹងទេ?

ខ៖ ហ៊ីពិបាកនិយាយណាស់ ដឹងដែរតែខ្លាចក្រែងលោរនិយាយខុសហាំ!!

ក៖ ម៉េចទៅពូ?

ខ៖ មិនដឹងដែរ ឥឡូវគេមិនអោយរៀនប្រវត្តិសាស្រ្តផង គឺយើងនិយាយអត់បានប្រវត្តិសាស្រ្តមើលសៀវភៅចេះណាស់!!

ក៖ ហ៊ឺ!!

ខ៖ អាហ្នឹងនិយាយទៅខ្មែរក្រហមពិបាក ណាស់!!

ក៖ ប្រវត្តិវញ៉ែវញ៉ែច្រើនណាស់ពូហេ??

ខ៖ វញ៉ែញ៉ែច្រើនណាស់ អាហ្នឹងនិយាយទៅមានជនបង្កប់អ្នកចង់បានទឹកដីយើងហ្នឹងគេបង្កប់តើ!!

ក៖ ហ្នឹងហើយ។យើងនិយាយអត់ចំឈ្មោះផងគេម៉េចដឹងបង!!គ្រាន់តែនិយាយអ្នកណាជនបង្កប់ៗហ្នឹង!!

ខ៖ អត់ដឹង !!៣ឆ្នាំ៨ខែខំធ្វើចង់ងាប់ស្រូវពោតសណ្តែកណោះយកទៅចិនណោះ។

ក៖ ញ៉ុមឮអ្នកណាគេនិយាយថាមួយណាក៏ទៅចិនអ្នកណាគេនិយាយក៏ទៅតែចិន។

ខ៖  ចិនជួយ !មហាមិត្ត។

កៈ មហាមិត្តតាំងពីដើមអត់ដឹងថាម៉េចហោ!!ពូ។

កៈ មហាមិត្តចង់យកទឹកដីយើងយូរហើយ។

ខៈ កាលហ្នឹងបានចង់ធ្វើគ្រូខ្មែរ ចង់បានស្រាវជ្រាវពីប្រវត្តិយើងតាំងពីតែអ៊ុងប្រវត្តិធៀវគីអីហាំ!!កៈ ហ៊ឺៗ!!ចាំ!!

ខៈ កាលហ្នឹងអត់ទាន់ចេះអក្សរទេ ឃើញគេជិះយន្តហោះគេបាច់ត្រាកទំលាក់ចុះអ្នកចេះអក្សរអាន។

កៈ អីគេធៀវគីឈ្មោះមនុស្សមែនពូហ្នឹងហី?

ខៈ អាហ្នឹងងារពួកយៀកកុង យួនហ្នឹង។

កៈ ចាំ!!

ខៈ អាហ្នឹង យើងចង់រៀនគ្រូខ្មែរដើម្បីអាប្រវត្តិហ្នឹងមកយើងបង្រៀនសិស្ស។

កៈ ហ្នឹងហើយ។

ខៈ ដល់តែ ដល់តែយើងចាប់ផ្តើមរៀនចេះយល់ដឹងពីអក្សរសាស្រ្តទៅគេអត់អោយដឹងទេតែកូនខ្មែរដឹង!!

កៈ សងសឹកហោ?

ខៈ អាហ្នឹងវាត្រូវហើយខ្លាចអីចឹង ដឹងទៅអាចដឹងបាតុកម្មអីមួយហ្នឹងហាំ!!កៈ ចាំ!!ខៈ អាហ្នឹងគឺធ្វើអោយខ្មែរល្ងង់។

កៈ ចាំ!!

ខៈ អីចឹងយើងណោះចង់ធ្វើគ្រូ អត់ទុកចិត្តទេ។

កៈ ហ៊ឺៗ!!

ខៈ អត់ទុកចិត្ត បានអីចឹងបានគ្រូមួយកម្ពុជាក្រោមមកបង្រៀនវៀតណាមវៀតណាមអោយបង្រៀនហាំ!!

ក៖ ចាំ!!

ខ៖ បង្រៀនមួយម៉ោងៗ សួរគាត់ទៅគាត់ខ្មែរកម្ពុជាក្រោម មានតែវៀតណាមទេដែលយើងរៀនទៅទទួលសញ្ញាបត្រអី អត់ណារៀន។

ក៖ លន់ នល់ ជំនាន់លន់ នល់ ហ្នឹងមែនពូ?

ខ៖ ជំនាន់ញ៉ុមរៀននៅតាខ្មៅហ្នឹង!!

ក៖ ហ្ហ៎!!

ខ៖ ដល់ហើយចេះតែរាប់អានគាត់ទៅ កូនគាត់ស្រីម្នាក់ដែរ រៀនជាមួយខ្ញុំហ្នឹង ចេះតែសួរប្រវត្តិទៅហ្នឹង គាត់ថាល្អដែរអាហ្នឹងហ្ហ៎ តែគាត់អាហ្នឹងគាត់ក្រប្រាប់យើងអាហ្នឹងគេអត់អោយរៀនទេប្រវត្តិសាស្រ្តខ្មែរ។

ក៖ ព្រោះអីចឹងបានញ៉ុមសំភាសន៍ទៅហ្នឹងដើម្បីទុកអោយសល់ទៅកូនចៅជំនាន់ក្រោយអោយគាត់បានរៀនពូហាំ!!

ខ៖ ទោះឥឡូវក៏អត់ដែរឥលូវ។

ក៖ រៀនតែគោលៗហ្នឹងហី!!អត់មានលំអិតអីផង។

ខ៖ អត់ទេ។

ក៖
តែដល់ពេលសំភាសន៍មួយនេះគឺសំភាសន៍អំពីជីវិតមនុស្សមួយៗម៉ង!!ឆ្លងកាត់អីចឹងហាំ!!ពូហាំ!!

ក៖ ពូពេលជំនាន់លន់ នល់ហាំអើរមានដែរអើរឃើញទន្លេនេះអីវ៉ាន់ដោយសារគេថាសម្លាប់យួនអីវ៉ាន់ បណ្តែតទឹកអីវ៉ាន់ហ្ហ៎!!ពូមានដែលដឹងរឿងហ្នឹងទេ?

ខ៖ កាលហ្នឹងញ៉ុមទាន់ដែរញ៉ុមនៅទូច!!នៅទូចហើយឮបងៗគាត់និយាយដែរ។

ក៖ ថាម៉េចខ្លះទៅពូ?

ខ៖ ឮឮបងៗនិយាយថាឮចាស់ៗថាខ្មោចបណ្ដែតទឹកអីវ៉ាន់ហ្នឹងតែវាមិនច្រើនទេ !!

ក៖ ហ៊ឺៗ!!

ខ៖ ឃើញទូកទូកវាទៅហាំ!!

ក៖ ចាំ!!

ខ៖ គ្រាន់តែឆ្លល់តាម៉េចមិនហូបទឹកទន្លេ ទៅរែកទឹកបឹងណោះវិញ!!ទៅទូចហាំពេលហ្នឹង!!

ក៖ ហ៊ឺៗ!!

ខ៖ ដឹងហាពេលហ្នឹងដឹងហាំ!!ហើយពេលជិតសង្គ្រាមហ្នឹង លន់ នល់ស្រែកតាមវិទ្យុញ៉ុមស្ដាប់។

ក៖ ម៉េចវិញទៅពូ?

ខ៖ ជាមួយចាស់ៗហ្នឹងគាត់ស្រែកថាស្ដីបងប្អូនរួមជាតិម៉េចទេមើលជីតមកលុកលុយហើយមើលមួយទៅមួយម៉េចទេ!!ចាស់ប្រាប់ថាស្ដាប់មើលទៅ។

ក៖ ពូគិតថាលន់ នល់ គាត់ស្នេហាជាតិអត់?

ខ៖ ហ្នឹងគាត់ស្នេហាដែរហ្នឹងតែមានអ្នកក្បត់ពីក្រោយ ក្បត់គាត់ពីក្រោយហាំ!!

ក៖ ហ្ហ៊ី!!

ខ៖ លន់ នល់ហ្នឹងដើម្បីកុំអោយពួកអាធៀវគីមកយកទឹកដី។

ក៖ ហ៊ឺៗ!!

ខ៖ តែពួកអាអ្នកនៅពីក្រោយលន់ នល់ហ្នឹងវាក្បត់គាត់ហាំ!!

ក៖ ចាំ!!

ខ៖ មើលគាត់ហ្នឹងដូចប្រហារចោលអ៊ីចឹង ក្បត់ហ្នឹងហាំ អាហ្នឹងពិបាកណាស់ ប្រវត្តិបើសិនគេអោយរៀនវិញប្រវត្តិខ្មែរឈឺចាប់ណាស់អាហ្នឹង។

ក៖
អ៊ីចឹងពូចឹអ៊ីចឹងញ៉ុមចេះតែចង់និយាយជីកឬសជីកគល់អារឿងហ្នឹងដើម្បីដឹងហ្នំ!!មែនតើនៅពេលដែលស្តាប់ពីប្រវត្តិប្រជាជនខ្មែរ!!

ខ៖ ដល់ពេលឥឡូវគេដឹងណាស់ គេមើលតាមសង្គមហ្វេសប៊ុកហ្នំ ដឹងប្រវត្តិដូចយើងរៀន។

ក៖ តាមហ្វេសប៊ុក យូធូបអ៊ីចឹងទៅណោះ។ចាំ!!

ខ៖ គេអ្នកចេះដឹងគេមកនិយាយ!!

ក៖ ហ្នឹងហើយ។

ខ៖ ដូចថាយើងចង់អាហ្នឹងអ៊ីចឹងហាំ!!

ក៖ សម័យឥឡូវនិយាយបានតែពីរស្រុកក្រៅមកទេ បើនិយាយក្នុងស្រុកគឺថា!!

ខ៖ ហ៊ីងាប់បាត់ឥឡូវហ្នឹង។

ក៖ និយាយក្នុងស្រុកបានតែអ្នកណាស្និតស្នាលគ្នាអីវ៉ាន់ទេបានបាន។

ខ៖ ស្តាយក្មេងៗឥឡូវសាលាគេបង្កើតមួយកំនរវាអត់ខំរៀនទេ!!កាលជំនាន់ខ្ញុំរៀនងាប់ហើយ ទៅលបស្តាប់មើលមេរៀន អញមើលដែរ!!

ក៖ ចាំ!!អ៊ីចឹងពូតែតាមទន្លេពូអត់ដែលឃើញទេគ្រាន់តែឮបងប្អូន?

ខ៖ ឮឮកាលហ្នឹងទាន់ញ៉ុមនៅទូចណាស់។

ក៖ ចាំដល់ពេលអ៊ីចឹងដឹងទៅ?

ខ៖ បាទ!!

ក៖ អ៊ីចឹងសំរាប់ឥឡូវចូលដល់ជំនាន់ប៉ុល ពត ឥឡូវនិយាយពីជីវិតពូនៅក្នុងជំនាន់ប៉ុល ពតហាំ!!តើជីវិតពូជួបរឿងអីគេខ្លះ ពូអាចនិយាយរៀបរាប់អោយអស់មើល?

ខ៖ នៅក្នុងជំនាន់អាពតមុនដំបូងបែកឪពុកម្ដាយ ឪពុកម្ដាយគាត់ចូលអង្គភាព ដេកទៅជាមួយគ្នាមុងហើយប្រវែង២០ម៉ែត្រអីចឹងទៅ ហើយដេកទៅ។

ក៖ ហើយមូសខាំទេពូ?

ខ៖ មូសខាំដែរ តែខ្លាំងជាងគេគឺសង្កើច។

ក៖ សង្កើចអី!!

ខ៖ ពីព្រលប់ដេកសណ្ដាប់គ្នាដល់តែនៅក្មេងវាអើរបំរាស់ផ្ទុយគ្នាអីចឹងទៅណាស់!!នោមដាក់គ្នាហ្នឹងសុទ្ធតែសង្កើច។

ក៖ ចា៎!!ពូអាយុប៉ុន្មានឆ្នាំពេលហ្នឹង?

ខ៖ អាយុខ្ញង់ប្រហែល១២ ១៣អីហ្នឹង។

ក៖ ហ្នឹងហើយពូក៏ដឹងច្រើនដែរមែនទេពូ?

ខ៖ ដឹងដែរ!!

ក៖ ចា៎!!

ខ៖ ញ៉ុម១៣ ១៤ដែរជំនាន់ហ្នឹងហា៎!!

ក៖ ការងារពូអីគេខ្លះមុខតំណែងដែរប៉ុល ពតចាត់អោយពូធ្វើ?

ខ៖ កាលហ្នឹងខែហ្នឹងអោយបារព្រៃស្ងួង បារព្រៃស្ងួងអោយកសិករគេរ៉ាស់គេស្ងួងហា៎!!កន្លែងណាព្រៃក្រាស់ហ្នឹងយើងកាប់ដុតអីចឹងទៅធាក់រហាត់។

ក៖ រហាត់ទឹកហ្នឹងពូហោ? ដាក់ទឹកចូលស្រែ?

ខ៖ ហ្នឹងហើយ។

ក៖ ចា៎!!

ខ៖
ដាក់អញ្ចឹងទៅហើយដល់នៅហ្នឹងហើយដល់ខែ៥អស់ការងារធ្វើគេអោយទៅនេះរោងចក្រថៃ ហ្គេីរនេះ ។

ក៖ ចាំ!!

ខ៖ កន្លែងហ្នឹងបឹងហាំ!!

ក៖ ហ៊ឺៗ!!

ខ៖ គេអោយទៅដេកហ្នឹងកាប់ព្រៃតាមភូមិហ្នឹងទៅដល់ថ្នល់ជាតិហ្នំ!!

ក៖ ចាំ!!

ខ៖ ហើយបានអាគ្រាក់ភ្នួរតាមក្រោយគាស់អាកូនចេកហ្នឹងតាមអញ្ចឹងទៅ។

ក៖ ចាំ ពេលហ្នឹងពូសំបូរផ្លែឈើច្រើនអីណាស់មែនទេពូ?

ខ៖ ហ្នឹង កាលហ្នឹងសំបូរខ្នុរណាស់។

ក៖ តែហូបបានទេ?

ខ៖ ខ្នុរហាំរបបមួយរទេះៗគេអោយកុមារហាំ!!គេដឹកយកមកអោយកន្លែងធ្វើការ ហូបទៅ។

ក៖ ការហូបចុកអត់ពិបាកទេពូហី?

ខ៖ ហ៊ឺពិបាកហូបអត់ឆ្អែត យើងនៅកុមារគេមិនសូវយកចិត្តទុកដាក់កាន់ហាំ!!

ក៖ ហ៊ឺៗ!!

ខ៖ យប់ឡើងយើងមានដំឡូង យើងលួចគាស់ដំឡូងដុតភ្នកគោទៅ ហូបទៅ។

ក៖ តែបើដុតអោយដឹងក៏ពិបាកដែរពូហី?

ខ៖ អត់អីទេ គ្រាន់តែមេកងស្តីអោយយើងអ៊ីចឹងទៅណាស់ ដាក់ផែនការយើងធ្វើការធ្ងន់ជាងគេបន្តិចទៅ។

កៈ ចាំ!!

ខៈ វាអ៊ីចឹង នៅកុមាររាងធូរបន្តិច ។

កៈ ហ៊ឺៗ!!

ខៈ បើយើងទៅយុវជនអត់បានទេ។

កៈ តែពូពេលហ្នឹងមានបានទៅយុវជនអីហ្នឹងគេទេពេលធំ?

ខៈ អត់។

កៈ នៅតែកងកុមារហ្នឹងហេ?

ខៈ ហ្នឹងហើយ។

កៈ ពូមានដែលឃើញឮអ្នកណាគេនិយាយអំពីការសម្លាប់មនុស្សអីវ៉ាន់ទេ?

ខៈ ដែលតែឃើញគេបណ្តើរ។

កៈ ម៉េចទៅ?

កៈ ដើរតាមផ្លូវ។

កៈ ម៉េចពូ?

ខៈ ដើរតាមផ្លូវហ្នឹងគេចងទៅយុវជន៤ ៥នាក់បណ្តើរ ក្មេងទូចៗអ៊ីចឹងទៅ។

កៈ ចាំ!!

ខៈ បណ្តើរ!!

កៈ អើរមនុស្សធំមួយបន្តើរគេ៤ ៥នាក់អ៊ីចឹងទៅ?

ខៈ ក្មេងស្ពាយកាំភ្លើងហ្នឹងហាំ!!

កៈ ចាំ!!

ខ៖ លើកអូសជីដពោកៗហ្នឹងហា!!

(ប្អូនលោកពូ)៖កូនក្មេងអ្នកបណ្ដើរមនុស្សធំ។

ខ៖ ចុះបើចងជាប់ហើយ ក្បាលជង្គង់ប៉ុនៗនេះ សុទ្ធតែឆ្អឹងហាំ!!មើលរូបគុកទួលស្លែងអារូបមនុស្សគេស្វែងមនុស្សហ្នំ!!

ក៖ ចាំៗ!!

ខ៖ មនុស្សយើងអីចឹងរៀងអាពត ដោះអាវមកឡើងឆ្អឹងជំនី។

ក៖ រាប់ឃើញទាំងអស់ម៉ងពូហេ(រាប់ឆ្អឹងជំនីបានស្គមពេក)?

ខ៖ អ្នកសំបូរអើស៊ីមានតែកុមារនៅភូមិទេ មកភូមិមានចេកមានដំឡូងអីចឹងទៅណាស់។

ក៖ ចាំ!!

ខ៖ យើងចុះបឹងមានក្ដាមខ្យង មើមព្រលិតអីទៅ ហើយបើពួកទៅកំលាំងស្រួចស្រែអំពិលនោះអត់ អត់មានទេអត់មានអីហូបទេ។

ក៖ ចាំៗ!!

ខ៖ សំបូរត្រីតែដុតអត់បានទេ។

ក៖ ចាប់គឺអត់បានម៉ង?

ខ៖ ហ៊ីតែឃើញផ្សែងហុយសុទ្ធហើយ ហើយអ្នកណាទៅហ៊ានដីស្រែអំពិលកាប់ទៅចេញភ្លើង ចេញភ្លើងហាំ ហើយចុះដាក់១៥ម៉ែត្រអីទៅក្រឡាអីទៅងាប់ហើយ។

ក៖ ចេញភ្លើង?

ខ៖ រឹងណាស់!!

ក៖ ហ្នំ!!

(ប្អូនស្រីលោកពូ)៖ដូចយើងខៃប្រាំងអីចឹង។

ខ៖ ម៉េចហើយថាសមរភូមិស្រួច ។

ក៖ ហ៊ឺ!!

ខ៖ យកទៅលត់យើងងាប់ហាំ!!

ក៖ គេអត់សម្លាប់ទេតែគេយកទៅអោយវេទនាអ៊ីចឹងម៉ងហោ?

ខ៖ វេទនា។

ក៖ ចុះឪពុកម្តាយពូពួកគាត់ម៉េចដែរ?

ខ៖ សុទ្ធតែនៅរៀងៗខ្លួនទៅណាស់!!គាត់នៅខាងកសិករភ្ជួរដីមួយក្រុមទៅគាត់អ៊ីចឹងទៅពុកចង់ជួបកូនកូនចង់ជួបពុកអត់បានជួបទេ ដូចញ៉ុមនិយាយអ៊ីចឹងឃើញគាត់គេម៉ង!!

ក៖ ហេងហើយពូបានគេច។

ខ៖ ឃើញអាអូនអាអូន។មិនមែនតែញ៉ុមទេគ្រប់គ្នាហ្នឹង អោយតែឃើញគាត់មកហើយហើយគាត់មកមិនមែនម្នាក់ណាដើរមួយជួរដូចយើងដែរហ្នឹង ។

ក៖ ហ៊ឺ!!

ខ៖ ឃើញព្រុចៗគេច។

ក៖ ពូទាហានអាពតនៅគ្រប់កន្លែងម៉ងហោ??
ខ៖ កាលជំនាន់សង្គ្រាមហ្នឹង?

ក៖ ហ្នឹងហើយ។

ខ៖ ទេអាហ្នឹងដូចថានៅតាមកន្លែងវា ដូចថាចង់មកកន្លែងណាវាមកកន្លែងហ្នឹងយប់ឡើងថ្ងៃអត់ឃើញទេ!!ថ្ងៃមានឃើញណា។

ក៖ ហើយអ៊ីចឹង យើងបានអីហូបទៅ អត់អីដែរតើហីវាមិនឃើញដែរមិនព្រមហូបអីពេលថ្ងៃទៅ!!

កៈ
មិនដឹងទេពេលហ្នឹងចាស់ៗគាត់ដាំបាយស្មើរហ្នឹងហូបហើយអស់ហើយអត់មាននៅចាំអីយប់ដូចឥឡូវហ្នឹងទេ!!

កៈ ចាំ!!

ខៈ ហូបហើយខ្ចប់វេចហើយអស់ហើយអស់។

កៈ ពូអ្នក១៧ឬក៏អ្នកមូលដ្ឋាន?

ខៈ ១៧ គេជំលៀសទៅលើ ។

កៈ ហ៊ឺ!!

ខៈ អ្នកមូលដ្ឋានទៅណោះ!!

កៈ តែភាគច្រើនញ៉ុមឮគេនិយាយបើសិនជាអ្នកមូលដ្ឋានហា អាហ្នឹងអត់សូវអីប៉ុន្មានទេ ដល់ពេលអ្នក១៧ហ្នឹងស្លាប់ច្រើនជាងពូហេ?

ខៈ ហ្នឹងហើយ គេថាពួកខ្មាំង គេហៅយើងខ្មាំង។

(ប្អូនស្រីលោកពូ)ៈគេធ្វើទារុណកម្មខ្លាំង។

ខៈ កាន់ជើងខ្មាំង ទៅណោះគេហៅពួកខាងខ្មែរក្រហមហ្នឹង។

កៈ កាន់ជើងគេហ្នឹង !!ហ្ហ៎!!ហ្នឹងហើយញ៉ុមយល់ហើយញ៉ុមទឹមយល់ទេនេះ អីចឹងពួក១៧មានន័យថាខ្មាំង ដល់ពេលពួកមូលដ្ឋានពួកកាន់ជើងប៉ុល ពតហ្នឹង!!

ខៈ ហ្នឹងហើយ ពួកខ្មែរក្រហមហ្នឹង កាលហ្នឹងគេនេះ គេគៀរត្រឹមផ្ទះឡាញ់ ណេនេះ ផ្ទះទិញខ្សែហ្នឹងហាំ!!

កៈ ចាំ!!

ខៈ ហ្នឹងពួកខ្មែរក្រហមគេគៀរទៅហ្នឹងទៅ ពួកញ៉ុមនៅត្រឹមហ្នឹងទៅច្បារអំពៅហ្ហ៎!!

កៈ គេកាត់តំបន់ហើយហ្នឹង។

ខ៖ ខ្មែរក្រហមនៅត្រឹមហ្នឹង លន់ នល់ នៅត្រឹមហ្នឹង ហ្នឹងប្រឡោះកណ្ដាល។

ក៖ តែពូពេលជំនាន់ ដល់ពេលចូលដល់ប៉ុល ពតមែនទែនទៅបាត់លន់នល់អស់រលីងហើយមែនទេ?

ខ៖ ពេលហ្នឹងគេសម្លាប់ចោលអស់ !!២៤ម៉ោងខ្វេច!!

ក៖ ចំ!!

ខ៖ ទាន់ពេលហ្នឹង ពេលហ្នឹងមិត្តពីហ្នឹងទៅទៅតាមផ្លូវបង់អង្គាញ់នេះហើយអាប៉េសេអញ្ចេះទាហានងាប់
អោយតែវាសម្លាប់វាវះកំភួនជើងហើយ។

ក៖ ម៉េចអ៊ីចឹង?

ខ៖ មិនដឹងសញ្ញាគេ!! ទាហានហ្នឹងហាំពួកខ្មែរក្រហមហ្នឹង!!

ក៖ ហ៊ឺៗ!!

ខ៖ សម្លាប់ទាហានលន់ នល់ហ្នឹងគឺវាវះកំភួនជើងមួយចំហៀងហើយ ។

ក៖ ចាំៗ!!

ខ៖ យកអាជំពុះទង់ហ្នឹងហាំឈូតៗ។

ក៖ អើយស្រៀវណាស់ពូ!!ញ៉ុមឆ្ងល់ណាស់បានជាមួយៗខ្មែរគ្នាឯងសោះថីបានកើតចិត្តគំនិតអើរសម្លាប់គ្នា។

ខ៖ កាន់ម្ខាងម្នាក់ដូចឥឡូវអ៊ីចឹង!!អាហ្នឹងពិបាកណាស់ អាហ្នឹងវាវាអ៊ីចឹងហើយអាខ្មែរក្រហមហ្នឹង គេបង្កប់ ខ្មែរយើងហ្នឹងតែគេបំពាក់គេបង្កប់យើងនោះពួកខាងកើតហ្នុំ!!គេបង្កប់ដើម្បីយកទឹកដីខ្មែរហ្នឹង ដល់ឥឡូវវាបានសំរេចហើយខ្មែរក្រហមមួយក្ដាប់តូចហ្នឹង។

ក៖ ចាំ!!

ខ៖ ដល់យើងស៊ីអត់ស៊ីឃ្លានគេ ចង់ធ្វើសង្គ្រាមគ្រាន់តែញុះញង់បន្តិចទៅពឹងគេឃើញទេ ពឹងបានពឹបគេពែងអ្នកស្នេហាជាតិចោល ល្អៗចោល។

ក៖ ហ៊ឺៗ!!

ខ៖ បានវញ៉េរញ៉ៃហ្នឹង។

ក៖ កាលណាចប់ទេពូអើយស្រុកយើងនេះ មានភាគបញ្ចប់អត់ទេ។

ខ៖ ហ៊ឺមិនងាយទេ ទាល់តែតាមពុទ្ធទំនាយហ្នំ!!រាល់ថ្ងៃអត់ គ្រាន់តែវាតូចចិត្តខ្លួនឯងដែរហាំ!!

ក៖ ចាំ!!

ខ៖ ខូចចិត្តថាកូនខ្មែរ យើងអត់ហ៊ានធ្វើអីយួនអេតចាយម្នាក់ អត់ហ៊ានធ្វើអីវា។

ក៖ ពេលមុនហាទឹកដីយើងឡើងជាប់ព្រំប្រទល់ប្រទេសចិនហ្នំពូហាំ រួមៗៗៗៗៗៗៗ!!

ខ៖ អឺចឹងបានថាពិបាកណាស់ យើងមើលតែឃើញគ្រួសារហ្នឹងតូចមួយកូនតែ៤នាក់ទេ រកព្រឹកចង់ខ្វះល្ងាច
!!ចុះយកកូន២នាក់១នាក់មកនៅជាមួយហាំអឺចឹងវាជួយស៊ីជួយបំផ្លាញវាអត់ស្តាប់យើងទេណាស់ អាហ្នឹងអឺចឹង ហ្នឹងហើយអឺចឹងឃើញទេ ប៉ុន្មានលាននាក់ស៊ីទាំងអស់ក្តាម ខ្យង គីងគក់ កង្កែបអីហ្នឹងខ្ទេចអស់ហើយ។

ក៖ ហ៊ឺ!!! សម្លាប់អស់រលីងហើយជំនាន់ហ្នឹង។

ខ៖ វាមកជួយស៊ី!!!

ក៖ ចាំ បងប្អូនពូមានអ្នកណាគេស្លាប់នៅក្នុងជំនាន់ប៉ុល ពតទេ?អត់ណាមិញហី??

ខ៖ បងប្អូនបង្កើតហី?

ក៖ ចាំ!!

ខ៖ បែកហើយស្លាប់។

ក៖ ហ្នំហ្នឹងហើយពូប្រាប់មិញដែរ!!ហើយចុះដល់ពេលបងប្អូនជីដូនមួយអីវ៉ាន់មានស្លាប់អីទេពូ?

ខ៖ ហ្អ៎!!

(ប្អូនស្រីរបស់លោកពូ)៖ច្រើនគ្នាណាស់រៀបរាប់មិនអស់ទេ!!

ខ៖ ឪពុកធំ ដេកអោបគាត់ហ្នឹង គាត់មកគាត់អត់ហូបអីទេ ដឹងថាគេរាយការណ៍ដឹងថាគាត់សក្ដិ៥ហ្នឹង ចុះគាត់ធាត់ដូចសក្ដិ៥ហ្នឹង។

ក៖ ហើយតាមពិតមិនមែនផងហី?

ខ៖ អត់ទេ ពីដើមគាត់បើកផ្ទះទឹក គាត់រកស៊ីទិញគោទិញអីហ្នឹងហា៎!!ក៖ ហ៊ីៗ!!ខ៖ ហើយមាឌគាត់ដូចសក្ដិ៥មែនហ្នឹងសរធាត់ ហ្នឹងគ្នាឯង សម្លាប់គ្នាឯង។ក៖ ហ៊ឺ!!ខ៖ ពួកព្យួរហើយដល់!!

ក៖ តាមពិតពូ អ្នកដែលរើសតាំងដើម្បីសម្លាប់គ្នាហ្នឹង អ្នកនៅក្នុងភូមិស្រុកតែមួយឬក៏មានតាំងមកពីណាវិញ?

ខ៖ វាច្រលូក កាលអត់ទាន់ច្រលូកតែស្រុកភូមិយើងអ៊ីចឹងមានអីហូប ចេះធ្មិចភ្នែកទៅអ្នកប្រធានកងហា៎!!

ក៖ ហ៊ីៗ!!

ខ៖ ដល់គេយកពួកព្រៃវែងស្វាយរៀងយកមកមិនសូវជាខ្លាំងទេតែពូកែរាយការណ៍ !!

ក៖ ហ៊ីៗ!!

ខ៖ពួកអ្នកពូកែសម្លាប់ពួកតាកែវ
ពួកតាកែវអាពួកហ្នឹងហើយវាដឹងគោលដៅស្រុកខ្មែរយើងហា៎!!

ក៖ ចា៎!!

ខ៖ អាហ្នឹងអ៊ីចឹង ពួកហ្នឹងមកវាធ្វើមេកងម៉ង គេដូរមេឃុំពីបៗ វាអត់ហ៊ានសម្លាប់ចោលផ្ទាល់ដៃទេវាធ្វើវាថានយោបាយខ្មាំង
កាលហ្នឹងនៅក្មេងខ្លាចណាស់យប់ឡើង ចោរព្រៃ!!ធ្វើអុកឡុកអោយយើងទៅដេញ តែតាមការពិតគេចង់សម្លាប់មេឃុំចោល មេឃុំខ្មែរយើងហា៎!!

កៈ ចាំ!!

ខៈ យល់យោគអ្នកស្រុកពេក អញ្ចឹងវាយកពូកតាកែវដាក់!!

កៈ អត់ស្គាល់។

ខៈ អាហ្នឹងចេះយួន ពូកអាហ្នឹងចេះយួនហាំ!!

កៈ ពូកអាជិតព្រំដែនមក!!

ខៈ ហ្នឹងហើយ។

កៈ មិនស្រួលជនជាតិហ្នឹងផងហីមិនស្រួលហី??

ខៈ ពិបាកនិយាយណាស់ រឿងអាអស់ ពិបាក។

កៈ សម្លាប់រុងគៀលខ្លាំងម៉ងពូណោះពេលហ្នឹង?

ខៈ ហ្នឹងហើយ!!កៈ ហុីៗ!!ខៈ ពេលហ្នឹងបង្អាត់ហើយពេលហ្នឹង ដូចញ៉ុមនិយាយអ៊ីចឹងដំបូងអង្ករមួយខាំកន្លះខាំ ពោតទុំពអីហ្នឹងហាំ!!!យើងចាប់ផ្ដើមចូលហើយអង្គភាព។

កៈ ចាំ!!

ខៈ អង្គភាពហើយ!!

កៈ អ៊ីចឹងពូអាថ្ងៃដែលបែកដឹងថាជំនាន់ប៉ុល ពតហាំ ញ៉ុមឮគេនិយាយថាធ្វើនំបញ្ចុកធ្វើនំអន្សមអោយហូប ពូមានអញ្ចឹងដែរអត់?

ខៈ គេធ្វើដែរកាលមួយហឹកហ្នឹង មានមេទិញគេហាំ មេទិញគេដាក់ មើល១០ថ្ងៃគេអោយឈប់មួយថ្ងៃ ២០ថ្ងៃគេអោយឈប់មួយថ្ងៃ ដល់ថ្ងៃ៣០គេអោយឈប់មួយថ្ងៃទៀត។

កៈ មានដេអហូទៀត!!

ខៈ អាហ្នឹងគេអត់មានគិតរឿងខែរឿងអាទិត្យទេ!!១០ថ្ងៃ១០ថ្ងៃ!!

កៈ ហ៊ឺៗ!!

ខៈ ឈប់ហ្នឹងអត់ទៅណាទេ!! នៅភូមិហ្នឹងទៅក៏បានហូបឆ្ងាញ់ហូបឆ្អែតទៅ។

កៈ តែឮគេនិយាយថាមុនពេលអាវៀតណាមចូលហ្នុំ គេបំរុងផែនការដាក់ថ្នាំបំពុលសម្លាប់ខ្មែរហ្នុំពូ?

ខៈ ដាក់ដាក់នៅកងព្រៃកថ្មីនេះ ហើយពួកញុំមគេអោយទៅប្រជុំណោះ ចំពុះក្អែកហ្នុំ!!មួយភូមិហ្នឹងទៅទាំងអស់ ទាំងអស់វាបំរុងបោកគ្រាប់បែកហាំ!!!!តែដល់មេប្រពន្ធគណៈឃុំហ៊ិ គណៈឃុំយើងនេះ។

កៈ ហ៊ឺៗ!!

ខៈ ប្រពន្ធប្រពន្ធគេដឹង ដឹងគេចូលទៅអង្គុយជាមួយប្រជាជនហាំ!!

កៈ ចាំ!!

ខៈ ហើយពួកឆ្លបហ្នឹងហៅចេញអត់ចេញ តែប្រពន្ធគណៈភូមិចេញគេបោះគ្រាប់បែកចូលហាំ!!

កៈ ហ៊ឺ!!

ខៈ ហើយអ្នកនៅខាងព្រៃកថ្មីហៅប្រជុំកងគេហ្នឹងគេអោយហូបគេលាយហាំ!!

កៈ ចាំ!!

ខៈ ដល់យើងមកពីឃ្លានហូបហើយ ដល់មេកងគណៈកងនៅព្រៃកថ្មីហ្នឹង គេដឹងគេប្រាប់ថាកុំហូបកេះប្រាប់គ្នាហាំកុំហូបដាក់ថ្នាំពុលទេ។

កៈ ហ៊ឺ!!

ខៈ បានផ្អើលហ្នឹងហើយវៀតណាមបានដេញៗចូលមក។

កៈ អូយ!!ឆិត ញុំមឮគេថាញុំមឮហាំពូ ញុំមទៅសំភាសន៍ដល់កំពង់ចាមអីវ៉ាន់ហ្នុំឮដែរមីងថាគេដាក់គ្រាប់បែក។

ខៈ អាហ្នឹងគេធ្វើគ្រប់កន្លែង!!

កៈ នំបញ្ចុកហ្នឹង។

ខៈ តែធ្វើធ្វើអត់បានសំរេច។

កៈ ហ្នឹងហើយយួនចូលមក។

ខៈ ធ្វើអត់បានសំរេចទេ។ដូចថាមានអ្នកចិត្តធមិប្រាប់ហាំ!!កៈ ហ៊ឺៗ!!ខៈ ជាពិសេសអ្នកសេដ្ឋកិច្ចដាំស្លរហ្នឹងម៉ង!!!!!

កៈ ហ៊ឺៗ!!

ខៈ អ្នកដាំស្លរមិនមែនខ្សែតូចតាចណា!!

កៈ ចាំ!!

ខៈ ដល់គេអានិតប្រជាជនគេប្រាប់ហើយកុំហូប។

កៈ ហ៊ឺៗ!!

ខៈ ហើយយើងទៅហូបអីពុល។

កៈ ចុះគាត់ជាចំនែកមួយដែលដាក់ថ្នាំហ្នឹងដែរហ្នឹអីចឹងគាត់នេះ!!!!

ខៈ កាលហ្នឹងយើងហូបហើយ ឃ្លានផង ហើយមកហើយឃើញឈ្មុញទៀតមិនហូបប្លែក!!ដាក់តែ២ ៣ស្លាបព្រាមិនងាប់!!!

កៈ ហ្នឹងហើយ ។

ខៈ ថ្នាំពីដើមខ្លាំងចង់ងាប់។

កៈ ហ៊ឺ!!ចាំអញ្ចឹងពូបន្ទាប់ពេលបែកពីជំនាន់ប៉ុលពតមកពូរកស៊ីអីគេវិញ?ចូលរៀនហើយមានរកស៊ីអីទៀតទេ?

ខៈ ជួយការពុកម៉ែ ដាំននោង រែកទឹលម្លូវ មុនដំបូងដាំកាឆាយអញ្ចឹងទៅ រែកទឹកអត់ទាន់កើតអត់រួច ចេះដកស្មៅ ជ្រំគល់អីអញ្ចឹងទៅណាស់!!

ក៖ ចាំ!!

ខ៖ ព្រលឹមឡើងបេះផ្កាវាទៅ ដល់អស់កាឆាយដាំននោង អាហ្នឹងវែកទឹកកើតហើយ វាលែងទើសដី ប៉ោតហាំ។

ក៖ ចាំ!!ពូប្រពន្ធពូឈ្មោះអីគេមិញ?

ខ៖ ហ៊ុយ ស្រីញៀន។

ក៖ ហ៊ុយ ស្រីញៀន?

ខ៖ ហ្នឹងហើយ។

ក៖ អ្នកណាគេអ្នកដាក់ឈ្មោះអោយមីង?ម៉ែឪអីចឹងទៅមីងណោះ??អូខេអីចឹងលោកពូមួយនេះជាសំនួរមួយចុងក្រោយ តើលោកពូមានអីគេដើម្បីចង់ផ្ដែផ្ដាំកូនចៅខ្លះដើម្បីអោយគាត់ដូចជាអប់រំគាត់អោយម៉េចដែរពេលទៅអនាគតតអីទៅអីចឹងហាំ!!!

ខ៖ អានេះគំនិតញ៉ុមចង់តែប្រាប់ក្មេងៗជំនាន់ក្រោយឥឡូវហ្នឹង ជំនាន់ក្រោយទៀតចង់អោយវាថាអោយខំរៀនកុំអោយល្ងង់ កាលណាយើងចេះអក្សរច្រើនទៅគេបោកអត់សូវបាន យើងចេះគិតខ្លួនឯង។

ក៖ ចាំ!!

ខ៖ អ្នកដទៃបោកអត់បាន យើងអត់ចេះអ្នកដទៃគិតអោយហើយដល់គិតអោយវាល្ងង់អវិជ្ជាហ្នឹង យើងអត់ដឹងថាវាយកអីៗពីយើងទេ អញ្ចឹងហើយកូនខ្មែរអោយខំរៀនសូត្រទៅអោយចេះស្រលាញ់គ្នាកុំអោយចេះក្បត់ចិត្តគ្នាហាំ!! អោយចេះគិតគូរឡើងវិញ។

ក៖ ចាំ!!កុំអោយធ្លាក់ចូលដូចមុនៗទៀតពូណោះ?

ខ៖ ស្តាយស្តាយសម្តេចតាគាត់ខំធ្វើសង្គ្រាមរ៉ាំរៃរ៉ាំរៃដើម្បីកុំអោយពួកចោរសៀមចោរអើជីតខាងលួចទឹកដីយើងហាំ។

ក៖ ចាំ!!

ខ៖ ដល់ទីបញ្ចប់កូនចៅវាល្ងង់ វានាំគេមកហាំ!! គំនិតញ៉ុមញ៉ុមចង់អោយកូនចៅជំនាន់ក្រោយហ្នឹងអោយសិក្សាអោយខ្លាំងពីប្រវត្តិសាស្រ្តខ្មែរហ្នឹង!!

ក៖ ងើបឡើងងើបឡើង។

ខ៖ សំខាន់ណាស់អក្សរសាស្រ្តខ្មែរហ្នឹងរៀនអោយច្បាស់លាស់អោយដឹងថាពាក្យខ្មែរហ្នឹងសរសេរម៉េច!!!! ឥឡូវកែច្រើន ស្តាយត្រង់ថាសរសេរអក្សរឥឡូវពិបាក ដូចខ្ញុំវិញរៀនសរសេរឥឡូវពិបាក ពិបាកណាស់អក្សរឥឡូវ។

ក៖ រឹងដៃពូហោ?

ខ៖ អត់ទេ វាខុសខុសអក្ខរាវិរុតគេកែអញ្ចឹងហាំ ដល់យើងពីដើមរៀនដូចថាចំលើយ!!ចំចំម៉ងឥឡូវ ច ម ជើង ល ដាក់ស្រះ ី និង យ !!

ក៖ ហ្នឹងវាកែមានច្រើនមើរណាស់។

ខ៖ ហ្នឹងហើយ ដូចសំលាញ់អីហ្នឹង ចេញបទចេញបែប អាហ្នឹងអត់កែទេពាក្យសំលាញ់អក្សរសាស្រ្តខ្មែរយើងហ្នឹងហាំ!!! ជើងតំរួត ជើងសំរាយយើងអាចសរសេរបានអាហ្នឹង ជើងតំរួតយើងអាចចូលក្នុងអត្តសញ្ញាណបាន ហើយអាសំរាយហ្នឹងយើងអាចសរសេកម្មវិធីអីបាន វាអានស្រួលអាន ស្រួលមើល ស្រួលសរសេរវារហ័សណាស់ ។

ក៖ ហ៊ឺៗ!!

ខ៖ ហ្នឹងហើយដល់ក្មេងឥឡូវអោយវាសរសេរវាអត់អក្ខរាវិរុតចំទេ សូម្បីតែមើលវាច្រៀង វាច្រៀងវប្បធម៌មួយដែរហ្នឹងហាំ ដល់ច្រៀងតាមបែបតុងតាមបែកបរទេស។

ក៖ ហ្នឹងហើយឥឡូវវប្បធម៌អីច្រៀតចូលច្រើនណាស់ទាំងញ៉ុមទាំងគេ។

ខ៖ ដូចទូកអញ្ចឹង ឧទាហរណ៍ដូចទូកអញ្ចឹងផ្ទុកបានតែ៩នាក់១០នាក់អីទេដល់ឡើង២នាក់៣នាក់អីទៀតវាចង់!!

ក៖ ផើលៗ។

ខ៖ ហ្នឹងហើយ វាអញ្ចឹងហ៎!!វាចង់ស្រាលក្រោមហាំ!!ខ្មែរយើងស្រាលក្រោមត្រចៀកសរគេផ្លុំ!!

ក៖ បានតាមចិត្ត។

ខ៖ គេអោយលុយតែបន្តិចៗតាមពិតមានតែប៉ុន្មានក្រុមទេពូហីធ្វើអោយរីកវរហាំ!!ខ៖ ហ្នឹង!!ក៖ នាំអោយគេមួយប្រទេសរីកវរ តែឯងបក្សពួកឯងអញ្ចឹងហាំពូហាំ!!

ខ៖ យើងនិយាយបានតែគ្នាយើងស្ងាត់ៗទេ។

ក៖ ហ្នឹងហើយ។

ខ៖ ខ្លាចគេម៉ងហាំឥឡូវហាំ!!មើលទៅម្នាក់ៗខ្លាចគេម៉ង ខ្លាចគេម៉ង។

ក៖ ងើបបង្ក្រាប ងើបបង្ក្រាប អាណាខ្លាំង ហ៊ឺ!!

ខ៖ ដូចត្រីអញ្ចឹង គេឃុំហាំ ដំបូងគេយកតែត្រីស្តោរត្រីរ៉ស់ទេ គេប្រលែងអោយអាចង្វារ កំផ្លាញ ដល់ឥឡូវអត់ទេចាប់អាស្តោរអស់ហើយហ្នឹង សល់តែអាកំផ្លាយយកទាំងអស់ អាណាមាត់ជាងគេយកហ្អែងធ្វើស៊ីហើយហ្នឹងឧទាហរណ៍អាហ្នឹង ប្រទេសជាតិយើងអញ្ចឹង អញ្ចឹងបានតែនិយាយគ្នាស្ងាត់ៗ មានតែការសោកស្តាយ សោកស្តាយណាស់ប្រទេសជាតិវាមិនគួរណា!!

ក៖ ដល់ថ្នាក់ហ្នឹង។

ខ៖ ៣០ឆ្នាំជាងមិនគួរណាអ៊ីចឹង មិនគួរណាអោយគេមកយកអាយើងត្រូវបែរជាខុសសរបែរជាខ្មៅ។

កៈ អើយយ៉ាប់ណាស់!!!

ខៈ ក្មេងឥឡូវគេអ្នកស្វែងយល់ គេអ្នកចេះដឹងគេយល់គេកើតដូចគេកើតដឹងឃើញពីជំនាន់អាពតអីចឹងដូចអាអូនឯងរៀនអីចឹងហាំ អត់ទាន់ទេតែយកការចេះដឹងស្វែងយល់ហ្នឹងទៅពិចារណាទៅយល់ វាសឹងតែ១០០%ហើយដែលគេនិយាយអីចឹងអាហ្នឹងអីចឹង ពិតៗម៉ង!! ដឹងក្ដីមកសង្គ្រាមរហូត។កៈ ហ៊ឺៗ!!ខៈ កូនខ្មែរយើងបើកុំសង្គ្រាមហាំ ស្រករស្រករខ្ញុំមិនធម្មតាទេ។

កៈ ហ្នឹងហើយ។

ខៈ ម្នាក់ៗឡើងវិស្វករ អាំងស៊ីញើរស្អីៗ សាស្ត្រាចារ្យអស់ហើយ។

កៈ មិនរល់ដូចរាល់ថ្ងៃហ្នឹងទេពូអើយ!!

ខៈ រល់ មើលរាល់ថ្ងៃ អ្នកណាខំរៀនគេចេះ អ្នកណាបានតែបន្តិចៗឈប់រៀនអ្នកហ្នឹង!!

កៈ ពូបើអត់លន់ នល់ហើយនឹងប៉ុល ពត មិនដឹងថាប្រទេសយើងមិនដឹងខ្លាំងយ៉ាងណាទេណាស់ទេពូណាស់!!សាហាវម៉ង!!

ខៈ ត្រង់ហ្នឹងហើយបានគេបង្កប់ហ្នឹងហាំ !!

កៈ ចាំ!!

ខៈ គេចង់បានទឹកដីខ្មែរហ្នឹងហាំ ទឹកដីខ្មែរវាសំបូរធនធានសម្បត្តិធម្មជាតិរ៉ែអីច្រើន មកឥឡូវ!!

កៈ ទឹកដីមាសពេជ្រ!!មកឥឡូវខ្មេចខ្ទីដូចខ្ទឹមអស់ហើយរលីងម៉ងបង ពូ!!

ខៈ ហ្នឹងហើយ។

កៈ អីចឹងអរគុណច្រើនលោកពូដែលអោយសំភាសន៍លោកពូដ៏ក្បោះក្បាយ អញ្ចឹងមួយហ្នឹងញ៉ុមនឹងរក្សាទុកសំរាប់កូនចៅលោកពូក៏ដូចជាប្រជាជនខ្មែរជំនាន់ក្រោយ ដើម្បីអោយពួកគាត់ដឹងពីប្រវត្តិរបស់ យើងការរស់នៅជំនាន់ឥឡូវហ្នឹងហាំលោកពូចាំអីចឹងអរគុណច្រើនលោកពូ។